# ការទប់ស្កាត់ការឈឺចាប់

យើងអាចជួយទប់ស្កាត់ការឈឺចាប់ក្នុងវិស័យទន្តសាស្ត្រដោយៈ

ថ្នាំបំបាត់ការឈឺចាប់ ថ្នាំស្ពឹក ថ្នាំសណ្តំស្មារតី ថ្នាំសណ្តំ(សន្លប់)

**ថ្នាំស្ពឹក**

នៅក្នុងថ្នាំស្ពឹក យើងបញ្ឈប់ការបញ្ជូនរបស់សញ្ញាណទទួលអារម្មណ៍ ពីចុងសសៃប្រសាទទៅខួរក្បាល។ យើងធ្វើវាដោយចាក់សារធាតុគីមីធ្វើអោយស្ពឹកនៅចុងសសៃប្រសាទ រឺ តាមបណ្តោយផ្លូវរបស់សសៃប្រសាទ។ សកម្មភាពរបស់សារធាតុគីមី ដើម្បីបញ្ឈប់សញ្ញាណទាំងនេះ មានរយៈពេលខ្លីប៉ុណ្ណោះ បន្ទាប់មកអារម្មណ៍ទាំងអស់នឹងត្រលប់មកសភាពធម្មតាវិញ។

ថ្នាំស្ពឹកលាបនៅនឹងកន្លែង (topical anaesthesia)




ថ្នាំស្ពឹកលាបនឹងកន្លែង អាចមានជាប្រភេទ ចាហួយ ក្រែម រឺ ថ្នាំបាញ់ ហើយវាមានផ្ទុក Lidocaine រឺ benzocaine។

ពួកវា ត្រូវបានលាបលើអញ្ចាញ មុនពេលចាក់ថ្នាំ និង ជួយកាត់បន្ថយការទទួលអារម្មណ៍ពីផ្ទៃខាងក្រៅមុននឹងចាក់ថ្នាំស្ពឹក។ វាត្រូវការរយៈពេល២នាទីដើម្បីស្ពឹក ហើយវាស្ពឹកយ៉ាងហោចណាស់ប្រហែល១០នាទី។

ជួនកាល ពួកវាអាចគេយកមកប្រើមុននឹងវះបើកមុខ/កាត់ បូស និង មុនពេលយកពុម្ពធ្មេញ ប្រសិនបើអ្នកជំងឺងាយនឹងក្អួតចង្អោរ។

**អំពូលថ្នាំស្ពឹក (Anesthetic cartridge)**




សូលុយស្យុងថ្នាំស្ពឹកមាននៅក្នុងអំពូលកែវជាមួយឆ្នុកជ័រដែលអាចផ្លាស់ទីបាន។ វាមាន ២ចំណុះគឺ 1.8ml និង 2.2ml ដើម្បីត្រូវនឹងសឺរ៉ាំងប្រភេទខុសៗគ្នា។ ភ្នាក់ងារធ្វើអោយស្ពឹកនោះជាធម្មតាគឺ Lidocaine, Prilocaine រឺ Articaine។

ក្រៅពីភ្នាក់ងារធ្វើអោយស្ពឹក ក៏មាន ទឹកលាយអំបិល និងសារធាតុរក្សាគុណភាពផងដែរ។

នៅក្នុងអំពូលថ្នាំស្ពឹកភាគច្រើន ក៏មានសារធាតុធ្វើអោយសសៃឈាមរួមតូច (vasoconstrictor)។ សារធាតុគីមីនេះ ធ្វើអោយសសៃឈាមរួមតូច ដូច្នោះថ្នាំស្ពឹកមិនជ្រាបចេញពីកោសិកាលឿនពេកទេ នោះនឹងអោយស្ពឹកបានយូរ។ វាក៏មានន័យថា នឹងមានការហូរឈាមតិចនៅតំបន់នោះ។

ជាធម្មតា vasoconstrictor ដែលគេប្រើគឺ Adrenalin/Epinephrine ហើយក្នុងថ្នាំស្ពឹកប្រភេទ Citranest, Octapressin (felypressin) ត្រូវបានគេប្រើ។ Octapressin មិនត្រូវបានណែនាំអោយប្រើចំពោះស្ត្រីមានផ្ទៃពោះទេ។

ថ្នាំស្ពឹកដែលមានជាតិ Adrenalin/Epinephrine អាចបណ្តាលអោយចង្វាក់បេះដូងដើរលឿន ប្រសិនបើចៃដន្យចាក់ចូលទៅក្នុងសសៃរឈាម ដូច្នោះហើយសឺរ៉ាំងថ្នាំស្ពឹកដែលអាច aspirate គួរយកមកប្រើប្រាស់ ប្រសិនបើមានហានិភ័យនៃការចាក់ចូលទៅសសៃរឈាម។ Aspirating មានន័យថា ឆ្នុកជ័រត្រូវបានទាញថយក្រោយដើម្បីពិនិត្យមើល ប្រសិនបើចុងម្ជុលគឺនៅក្នុងសសៃឈាម--ឈាមពណ៌ក្រហមនឹងឃើញនៅក្នុងអំពូលថ្នាំស្ពឹក។

អំពូលថ្នាំស្ពឹកខ្លះមានឆ្នុកមួយដែលមានផ្នែកកណ្តាលទន់ដើម្បីរលាស់ថយក្រោយវិញ។

ថ្នាំស្ពឹកដែលមានជាតិ Adrenaline គួរតែប្រើដោយប្រុងប្រយត្ន័បំផុតចំពោះអ្នកដែលមានបញ្ហាបេះដូងធ្ងន់ធ្ងរ។




របៀបចាក់ថ្នាំស្ពឹកសំខាន់ៗ ៣យ៉ាង ប្រើមុនពេលព្យាបាល គឺ :



**Infiltration Injection**: ប្រើចំពោះធ្មេញលើ និង ធ្មេញក្រោមផ្នែកខាងមុខ។ សឺរ៉ាំងដោយប្រើម្ជុលខ្លី ត្រូវចាក់នៅជាប់នឹងចុងរឺសរបស់ធ្មេញ រឺកន្លែងដែលត្រូវធ្វើអោយស្ពឹក។

**Block Injection**: សឺរ៉ាំងដែលអាច aspirate ដោយមានម្ជុលវែងត្រូវបានប្រើ ហើយស៊កទៅជិតសសៃប្រសាទធំ ហើយត្រូវតែប្រុងប្រយ័ត្នកុំចាក់ចូលទៅក្នុងសសៃឈាមដែលនៅជិតខាង។

**Inferior Dental Nerve Block (IDB):** គឺប្រើដើម្បីធ្វើអោយស្ពឹកធ្មេញក្រោមទាំងអស់នៅផ្នែកម្ខាង។






 

**Intra-ligament injection** : សឺរ៉ាំងពិសេសត្រូវបានប្រើជាមួយអំពូលថ្នាំស្ពឹកចំណុះ 1.8ml ហើយនឹងម្ជុលខ្លីបំផុត។ ការចាក់ប្រព្រឹត្តទៅដោយអោយទន្តពេទ្យបង្ខំថ្នាំស្ពឹកអោយចូលទៅចន្លោះធ្មេញ និង ឆ្អឹង--Periodental ligament។ ការចាក់នេះត្រូវតែធ្វើទៅ**យឺតៗបំផុត** នៅខាងណាក៏បាននៃធ្មេញ។

ការចាក់ប្រភេទនេះ មានន័យថា មានតែធ្មេញមួយនោះប៉ុណ្ណោះ ដែលបានធ្វើអោយស្ពឹក គឺមិនមែនតំបន់នៅជុំវិញនោះច្រើនទេ។ ការចាក់នេះអាចនឹងមានសារៈសំខាន់ណាស់ចំពោះកុមារ ដោយសារកុមារទាំងនេះ មិនបានឃើញម្ជុលធំ ហើយវាមិនមានអារម្មណ៏ថាម្ជុលត្រូវបានចាក់ចូលទៅក្នុងអញ្ចាញរបស់ពួកគេ។

## **សុវត្ថិភាពនៃការប្រើម្ជុល**



បន្ទាប់ពី ម្ជុលត្រូវបានប្រើរួច វាត្រូវតែយកចិត្តទុកដាក់ ដោយការប្រុងប្រយ័ត្នខ្ពស់បំផុតដើម្បីចៀសវាងការបង្ករបួសដល់ទន្តពេទ្យ រឺ ជំនួយការទន្តពេទ្យ ហើយគំរបម្ជុលមិនត្រូវគ្របម្ជុលដោយប្រើដៃដោយគ្មានប្រើរបាំងការពារម្ជុលឡើយ។

ម្ជុលសុវត្ថិភាពពិសេស មានអោយប្រើប្រាស់ដែលមានបន្ទះជ័រ ដើម្បីការពារ និង អាចអោយដោះវាចេញពីសឺរ៉ាំង។

ម្ជុលក្រោយពីប្រើប្រាស់រួច ជានិច្ចជាកាលត្រូវតែដាក់វានៅក្នុងប្រអប់រឹងអាចបិតជិត ដែលអាច ដែលអាចអោយគេយកទៅដុតរំលាយបាន។



**គ្រោះថ្នាក់នៃថ្នាំស្ពឹក**

ការពន្យល់ណែនាំគួរត្រូវបានផ្តល់ជូនអ្នកជំងឺ មុននឹងចាក់ថ្នាំស្ពឹក ដូច្នោះពួកគេនឹងយល់អំពីអ្វីដែលនឹងត្រូវរំពឹងទុក។ អាចនឹងមានភាពមិនស្រួល ហើយជួនកាលមានការឈឺចាប់មួយចំនួន នៅពេលចាក់ថ្នាំនោះ--នេះដោយសារម្ជុលបានឆ្លងកាត់សាច់ដុំ រឺ សសៃប្រសាទ។ ការចាក់នោះក៏នឹងឈឺខ្លាំងដែរ ប្រសិនបើការចាក់នោះលឿនពេក។

អ្នកជំងឺគួរត្រូវបានគេប្រាប់មុនថា ឥទ្ធិពលថ្នាំស្ពឹកអាចមានរយៈពេល បីបួនម៉ោង ហើយពួកគេត្រូវតែយកចិត្តទុកដាក់កុំខាំអណ្តាត ថ្ពាល់ រឺ បបូរមាត់ដោយសារពួកគេមិនអាចមានអារម្មណ៍ដឹងនៅកន្លែងនោះឡើយ។ អាហារ និង ភេសជ្ជៈក្តៅ មិនគួរបរិភោគឡើយដើម្បីចៀសវាងការរលាកនានា។

អាចមានភាពមិនស្រួលមួយចំនួន (ឈឺតិចតួចណាស់) បន្ទាប់ពីថ្នាំស្ពឹកអស់ប្រសិទ្ធភាព ដោយសារមានការហូរឈាមទៅក្នុងជាលិកា និង សាច់ដុំនៅកន្លែងដែលម្ជុលបានចាក់ចូល ជាពិសេសជាមួយនឹងការចាក់ inferior dental block។

អ្នកជំងឺមិនត្រូវទុកអោយនៅតែម្នាក់ឯង បន្ទាប់ពីបានទទួលចាក់ថ្នាំស្ពឹកឡើយ ព្រោះករណីខ្លះអាចមានផលវិបាកកើតឡើង។

**ការសន្លប់** គឺជាបញ្ហាមួយដែលកើតឡើងជារឿយៗ បន្ទាប់ពីចាក់ថ្នាំស្ពឹក--ជាពិសេសនៅពេលធ្វើ inferior dental block ហើយថ្នាំស្ពឹកមួយចំនួនបានចាក់ដោយចៃដន្យចូលទៅក្នុងសសៃឈាម។ ការសន្លប់ គឺកើតឡើងជាញឹកញាប់ខ្លាំង ប្រសិនបើអ្នកជំងឺអង្គុយបញ្ឈរត្រង់ ប្រសិនបើអ្នកជំងឺពាក់ខោអាវច្រើនជាន់ ប្រសិនបើអ្នកជំងឺមានភាពភ័យខ្លាចខ្លាំង រឺក៏ប្រសិនបើអ្នកជំងឺមិនបានបរិភោគអាហារ។ វាមានសារៈសំខាន់ក្នុងការដែលជំនួយការទន្តពេទ្យជួយអោយអ្នកជំងឺសំរាករីបន្ធូរអារម្មណ៍ដោយការពន្យល់ណែនាំល្អៗ ពីអ្វីដែលនឹងកើតឡើង ដោយធានាថាមិនមានសំលៀកបំពាក់លើសច្រើន រឺ សំលៀកបំពាក់តឹងនៅក ហើយនិយាយទៅកាន់អ្នកជំងឺក្នុងពេលកំពុងដំណើរការព្យាបាល។

**កំណកឈាម--**ដោយសារការចាក់នោះត្រូវបានធ្វើឡើង នោះម្ជុលអាចធ្វើអោយខូចខាតដល់សសៃឈាម ហើយជាលិកាអាចចាប់ផ្តើមហើម (កើនឡើងទំហំ)។ វាអាចធំខ្លាំង--វាអាចក្រហម ហើយប្តូរទៅជាពណ៌ត្នោត រួចមកលឿងក្នុងរយៈពេល ១០ថ្ងៃក្រោយ។ ការផ្លាស់ប្តូរពណ៌ (រឺ ស្នាមជាំ) អាចរាលដាលចុះក្រោមរហូតមកដល់ ក។

**ហាមាត់មិនរួច--**បន្ទាប់ពីធ្វើ inferior dental block ប្រសិនបើមានការខូចខាតដល់សសៃឈាម រឺ សាច់ដុំហើយមានការហើម វានឹងពិបាក និង មានការឈឺចាប់ក្នុងការហាមាត់--វាត្រូវបានគេហៅថា trismus និងមានរយៈពេលបីបួនថ្ងៃ។

**នៅបន្តស្ពឹក**--នេះអាចកើតឡើងក្នុងករណីម្ជុលបានធ្វើអោយសសៃប្រសាទខូចខាតអំឡុងពេលចាក់--វាកំរណាស់ ទោះបីជាទន្តពេទ្យជារឿយៗ ព្យាយាមចាក់ទៅដល់សសៃប្រសាទដើម្បីធ្វើអោយស្ពឹកវាក៏ដោយ។ ប្រសិនបើមានការខូចខាតកើតឡើង វាអាចត្រូវការរយៈពេលពីរបីសប្តាហ៍ រឺ រាប់ខែមុននឹងមានការទទួលអារម្មណ៍ធម្មតាឡើងវិញ។

**ថ្នាំសណ្តំស្មារតី**

- នេះគឺជាវិធីមួយនៃការកាត់បន្ថយការភ័យខ្លាច និង ការឈឺចាប់ របស់ដំណើរការព្យាបាលធ្មេញ
- មិនមានការបាត់បង់ស្មារតីទេ
- មាន២របៀបនៃការប្រើប្រាស់ថ្នាំសណ្តំស្មារតីៈ



**ការសណ្តំដោយការស្រូបៈ** អ្នកជំងឺស្រូបនូវកំហាប់ដ៏មានសុវត្ថិភាពនៃឧស្ម័ន Nitrous oxide និង អុកស៊ីសែន ហើយបន្ទាប់មក អ្នកជំងឺមានអារម្មណ៍ធូរស្រាលរីសំរាក។ ការឈឺចាប់បានបាត់បង់អស់ជាច្រើន។ ការសណ្តំដោយស្រូប គឺជួនកាលត្រូវបានគេប្រើរួមជាមួយថ្នាំស្ពឹក ដែលផ្តល់លទ្ធផលជាការព្យាបាលដែលគ្មានការឈឺចាប់ទាំងស្រុង។ សកម្មភាពជាប្រក្រតីអាចនឹងត្រលប់មកវិញភ្លាម១ បន្ទាប់ពី ការសណ្តំដោយស្រូបនោះ បានបញ្ចប់។

**ការសណ្តំដោយចាក់តាមសសៃវ៉ែន**

- នេះជាការធ្វើឡើងដោយការចាក់ចូលទៅក្នុងសសៃវ៉ែននៅក្នុងដៃ។
- មិនមានការបាត់បង់ស្មារតីទេ ប៉ុន្តែ ការភ័យខ្លាច និង ការឈឺចាប់បានបាត់បង់យ៉ាងច្រើនដើម្បីអនុញ្ញាត្តិអោយមានការព្យាបាលដែលគ្មានការឈឺចាប់។
- អាចនឹងមិនមានការចងចាំនូវអ្វីដែលបានកើតឡើងអំឡុងពេលព្យាបាល។
- ការសណ្តំដោយចាក់តាមសសៃវ៉ែន អោយលទ្ធផលទៅជាភាពធីងធោងបន្ទាប់ពីព្យាបាល។ ដូច្នេះ វាសំខាន់ណាស់ក្នុងការត្រូវកំដរអ្នកជំងឺពេលធ្វើដំណើរទៅផ្ទះ។
- ការបើកបរមិនត្រូវបានអនុញ្ញាតឡើយ ក្នុងអំឡុងពេលយ៉ាងតិច២៤ម៉ោង។

**ថ្នាំសណ្តំ (សន្លប់)**

- ថ្នាំសន្លប់អនុញ្ញាត្តិអោយទន្តពេទ្យធ្វើការព្យាបាលលើអ្នកជំងឺដែលបាត់បង់ស្មារតី
- វាមានសារៈសំខាន់នៅពេលការព្យាបាលពោរពេញដោយការឈឺចាប់ និង ការលំបាក ជាលក្ខណៈពិសេសណាមួយ
- ប្រសិនបើបញ្ហាខាងអារម្មណ៍ និង អាកប្បកិរិយារបស់អ្នកជំងឺ ធ្វើអោយទន្តពេទ្យមិនអាចធ្វើការព្យាបាលនៅក្នុងបន្ទប់ព្យាបាលបាន នោះថ្នាំសន្លប់អាចដោះស្រាយបញ្ហានោះបាន។
- ថ្នាំសន្លប់គួរតែប្រើប្រាស់ក្នុងមន្ទីរពេទ្យ រឺ បរិស្ថានស្រដៀងនេះប៉ុណ្ណោះ ហើយគួរប្រើប្រាស់ដោយអ្នកឯកទេសដាក់ថ្នាំសណ្តំ។